# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ the Asian International Justice Initiative**

ឆ្នាំទី១ លេខ ៣ សប្តាហ៍ទី ៣ (២០ ~ ២៣ មេសា ឆ្នាំ២០០៩)


## " សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស.២១ កាំង ហ្គិចអាវ ហៅ ឌុច"



## ១. សេចក្តីសង្ខេប

ការចោទសួរពីការបង្កើតមន្ទីរ ស-២១ បានចាប់ផ្តើមនៅថ្ងៃពុធ ទី២២ ខែមេសា ឆ្នាំ២០០៩ បន្ទាប់ពីប្រធានអង្គជំនុំជម្រះប្រកាសបញ្ចប់ការចោទសួរលើអង្គហេតុ និងការពិនិត្យភស្តុងតាងអំពីមន្ទីរ ម-១៣ ។ ដំណាក់កាលនេះ បានចាប់ផ្តើមធ្វើការចោទសួរទៅលើជនជាប់ចោទ អំពីការបង្កើតមន្ទីរ ស-២១ ។ កាលពីថ្ងៃចន្ទ័ និងថ្ងៃអង្គារនាសប្តាហ៍នេះ សាក្សីចុងក្រោយពីររូបត្រូវបានចោទសួរពីមន្ទីរ ម-១៣ គឺលោក **ចាន់ វឿន** និង លោក **ចាន់ ខន** ដែលជាអតីតអ្នកយាមនៅមន្ទីរនោះ ។ ពួកគេបានផ្តល់សក្ខីកម្មអំពីបទពិសោធន៏ កាលដែលនៅធ្វើការក្រោមបង្គាប់របស់**ឌុច** និងពីលក្ខខណ្ឌនៅមន្ទីរ ម-១៣ ។ ចំពោះសាក្សីទី១ **ឌុច** បានបដិសេធថា លោក **ចាន់ វឿន** មិនធ្លាប់ធ្វើការជាមួយគាត់ទេ ។ លើសពីនេះទៅទៀត សក្ខីកម្មដែលសាក្សីបានផ្តល់ ហាក់ដូចជាមិនស៊ីសង្វាក់គ្នាជាមួយសក្ខីកម្មដែលបានផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត ។ ហេតុដូច្នេះ នាំឱ្យមានភាពមន្ទិលទៅលើភាពអាចទុកចិត្តបានចំពោះសក្ខីកម្មនេះ។ ទោះបីជាយ៉ាងនេះក៏ដោយ វត្តមាន និងអត្តសញ្ញាណរបស់ **ចាន់ វឿន** ត្រូវបានបញ្ជាក់បន្ថែមដោយសក្ខីកម្មរបស់សាក្សី **ចាន់ ខន** ដែលត្រូវបានជនជាប់ចោទទទួលស្គាល់ថា ជាអតីតអ្នកធ្វើការក្រោមបង្គាប់របស់**ឌុច**នៅមន្ទីរ ម-១៣ ។ ក្រៅពីរៀបរាប់ថា **ឌុច** ជាមនុស្ស *ម៉ឺងម៉ាត់ ហើយម៉ត់ចត់ការងារ* សាក្សី **ចាន់ ខន** បានបន្ថែមថា គាត់គ្មានជម្រើសទេ នៅពេលដែលគេប្រាប់ឱ្យទៅបំរើការនៅមន្ទីរ ម-១៣ ដែលចំណុចនេះ **ឌុច** បានប្រាប់ថា ជាលក្ខខណ្ឌទូទៅសម្រាប់យុវជននៅ *តំបន់មូលដ្ឋាន* ។ សក្ខីកម្មរបស់ **ចាន់ ខន** ហាក់ដូចជាមិនស៊ីសង្វាក់នឹងចំណុចមួយចំនួនដែលលើកឡើងដោយ

**ឌុច** ប៉ុន្តែមានចំណុចដែលស្របគ្នានៅត្រង់ថា **ឌុច** មិនដែលបានសម្លាប់មនុស្សដោយផ្ទាល់ដៃទេ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបអំពីសក្ខីកម្ម

***សក្ខីកម្មរបស់សាក្សី ចាន់ វឿន :*** សាក្សី **ចាន់ វឿន** មានអាយុ ៥៦ឆ្នាំ បានអះអាងថាគាត់គឺជាអតីតអ្នកយាមនៅមន្ទីរ ម-១៣ ។ បើទោះបីជាយ៉ាងនេះក៏ដោយ **ឌុច** បានអះអាងថាសាក្សីរូបនេះមិនធ្លាប់នៅមន្ទីរ ម-១៣ ទេ ។ សាក្សី **ចាន់ វឿន** បានរៀបរាប់អំពីលក្ខខណ្ឌនៃការឃុំឃាំង របៀបសួរចម្លើយ និងការសម្លាប់នៅមន្ទីរ ម-១៣ ព្រមទាំងចរិកលក្ខណៈរបស់ **ឌុច** ។ សក្ខីកម្មនេះមិនស៊ីសង្វាក់គ្នាជាច្រើនចំណុចជាមួយចម្លើយរបស់ **ឌុច** ហើយមិនស្របគ្នាទៅនឹងចម្លើយដែលសាក្សីរូបនេះបានផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត ។ លើសពីនេះ វាហាក់ដូចជាមានភាពមិនច្បាស់លាស់ចំពោះអ្វីដែលសាក្សីរូបនេះបានឃើញ និងអ្វីដែលបានសន្មត់។ ដូច្នេះនាំឱ្យមានមន្ទិលអំពីភាពអាចទុកចិត្តបានលើសក្ខីកម្មនេះ ។

***សក្ខីភាពរបស់សាក្សី ចាន់ ខន :*** សាក្សី **ចាន់ ខន** គឺជាសាក្សីទីបី និងចុងក្រោយ ដែលបានផ្តល់សក្ខីកម្មអំពីអង្គហេតុនៅមន្ទីរ ម-១៣។ សាក្សីរូបនេះលើកឡើងថាកាលនោះគាត់មានអាយុ ១៣-១៤ឆ្នាំ នៅពេលដែលគាត់ត្រូវជ្រើសរើសឱ្យចូលបំរើការងារជាអ្នកយាមនៅមន្ទីរ ម-១៣ ក្នុងឆ្នាំ១៩៧៣ ។ នៅចុងឆ្នាំនោះ ឬប្រហែលជានៅដើម ឆ្នាំ១៩៧៤ គាត់ត្រូវគេចាត់ឱ្យទៅធ្វើស្រែ ។ បើទោះបីជាសាក្សី **ចាន់ ខន** បញ្ជាក់ថា គាត់មិនចង់ធ្វើការនៅមន្ទីរ ម-១៣ ក៏ដោយ ក៏គាត់គ្មានជម្រើសអ្វីក្រៅពីធ្វើការតាមបញ្ជាឡើយ ។ សក្ខីកម្មរបស់ **ចាន់ ខន** ហាក់ដូចជាខុសគ្នាជាមួយចម្លើយ ដែលបានផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត ។ ប៉ុន្តែចម្លើយដែលគាត់បានផ្តល់ក្នុងសវនាការហាក់ដូចជាស្របនឹងការអះអាងរបស់ **ឌុច** ថាគាត់មិនដែលបានសម្លាប់មនុស្សដោយផ្ទាល់ដៃទេ ហើយមានចំណុចមិនស៊ីសង្វាក់មួយចំនួនទៀតពាក់ព័ន្ធនឹងវត្តមានកុមារ និងបញ្ហាទឹកជំនន់នៅឆ្នាំ១៩៧៣ ។ បន្ថែមលើនេះ សាក្សី **ចាន់ ខន** បានលើកឡើងអំពីការកង្វះការថែទាំសុខភាពនៅមន្ទីរ ម-១៣ ។

***ចម្លើយឌុច អំពីមន្ទីរ ស-២១ :*** ការចោទសួរ **ឌុច** អំពីការបង្កើតមន្ទីរ ស-២១ ត្រូវបានចាប់ផ្តើមដោយរៀបរាប់អំពីហេតុការណ៍បន្ទាប់ពីមន្ទីរ ម-១៣ រហូតដល់ពេលដែលគេចាត់គាត់ឱ្យទៅធ្វើការនៅមន្ទីរ ស-២១ ។ ដំបូងឡើយ គាត់ជាអនុប្រធានមន្ទីរ ស-២១ ហើយ **ណាត** ជាប្រធាន ។ ក្រោយមកនៅ ខែមិនា ឆ្នាំ១៩៧៦ **ណាត** ត្រូវផ្លាស់ទៅធ្វើការនៅកន្លែងផ្សេង ចំណែក **ឌុច** ត្រូវបាន **សុន សេន** តែងតាំងជាប្រធានមន្ទីរ ស-២១ ។ **ឌុច** អះអាងថា **សុន សេន** ជាអ្នកចេញបញ្ជាឱ្យបង្កើតមន្ទីរ ស-២១ ។ អក្សរ *ស* តំណាងឱ្យសន្តិសុខ ឬសន្តិភាព ដែលមានពាក្យពេញថា *សន្តិបាល* ហើយលេខ *២១* គឺជាលេខដែល **ណាត** ជ្រើសរើស ។ **ឌុច** ពន្យល់ថា មន្ទីរ ស-២១ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ **សុន សេន** ហើយក្រោយមក **នួន ជា** នៅពេលដែល **សុន សេន** ជាប់រវល់នៅសមរភូមិមុខ។ គោលបំណងបង្កើតមន្ទីរ ស-២១ គឺដើម្បីឃុំឃាំង ធ្វើទារុណកម្មយកចម្លើយ និងកំទេចអ្នកទោស ។

### ខ. អំណះអំណាង/កង្វល់ដែលបានលើកឡើងនៅពេលសវនាការ

**ការលើកឡើងអំពីឯកសារមិនមានស្ថានភាពគតិយុត្ត :** នាសប្តាហ៍នេះ បញ្ហាឯកសារនៅក្នុងសំណុំរឿង ដែលគេមិនបានពិនិត្យពីភាពស្របច្បាប់ គឺបានសួរដេញដោលសារជាថ្មីម អំពីភាពអាចទទួលយកបាននូវឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និង ឯកសាររបស់ឧត្តមស្នងការសហប្រជាជាតិ (UNOHCHR) ។

បញ្ហានៃការទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ត្រូវបានលើកឡើងកាលពីសប្តាហ៍មុន នៅពេលចៅក្រម **Lavergne** សួរតទល់ឯកសារជាមួយនឹងជនជាប់ចោទ ដែលឯកសារនេះផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ចំពោះសាក្សីពីររូបដែលបានស្លាប់ទៅ ។ នៅពេលនោះអង្គជំនុំជម្រះសម្រេចថានឹងដោះស្រាយបញ្ហានេះនាពេលក្រោយ និងបង្គាប់មិនឱ្យភាគីទាំងអស់យោងទៅលើឯកសារ ដែលទាក់ទងនឹងសាក្សីទាំងពីររូបនោះទេ។ បញ្ហានេះបានកើតឡើងជាច្រើនលើកច្រើនសារ នៅពេលដែលមេធាវីដើមបណ្តឹងអន្តរជាតិក្រុម២ កញ្ញា **Silke** បានព្យាយាមសួរតទល់សាក្សី **ចាន់ ខន** ជាមួយព័ត៌មានដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) នៅឆ្នាំ២០០៣។ ក្នុងនាមសហព្រះរាជអាជ្ញាអន្តរជាតិ លោក **Alex Bates** បានលើកឡើងពីចេតនារបស់សហព្រះរាជអាជ្ញាចង់ឱ្យពិនិត្យនូវឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ពាក់ព័ន្ធនឹងឈ្មោះ **ឈិន សុធី** យោងតាមការិយាល័យសហចៅក្រមស៊ើបអង្កេតមិនអាចរកឃើញដានបានទេ។ បន្ទាប់មកអង្គជំនុំជម្រះបានឱ្យគ្រប់ភាគីធ្វើសំណូមពរដោយផ្ទាល់មាត់លើបញ្ហានេះ ។

ក្នុងនាមសហព្រះរាជអាជ្ញាលោក **Alex Bates** បានលើកហេតុផលថា សម្រាប់ឯកសារទាំងនោះ មាននៅក្នុងសំណុំរឿងរួចហើយ ការទទួលយកមិនគួរមានបញ្ហាទេ ចំណោទតែមួយគត់គឺថា តើឯកសារទាំងនោះមានតំលៃប៉ុណ្ណា។ លោក **Bates** បានលើកអំណះអំណាងរបស់គាត់ដោយផ្អែកលើវិធាន ៨៧(១) ដែលហៅថា *"ចំណុចចាប់ផ្តើម"* នៃភាពអាចទទួលយក។ វិធាន ៨៧(១) ចែងយ៉ាងច្បាស់ថា *"រាល់ភស្តុតាងទាំងអស់ត្រូវទទួលយក"* ។ យោងតាមលោក **Bates** ការជំទាស់នឹងការបញ្ចូលឯកសារក្នុងសំណុំរឿងគួរត្រូវបានលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត ក្រោមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង។ លោកបានលើកអំណះអំណាងបន្ថែមថា វិធាន ៧៦(៧) បានបញ្ជាក់យ៉ាងច្បាស់ថា *ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធាន* ។ ដោយសារតែអង្គភាពការពារក្តីខកខានមិនបានដាក់ពាក្យស្នើសុំដកចេញឯកសារនោះ នៅដំណាក់កាលស៊ើបអង្កេត ឥឡូវនេះឯកសារទាំងនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងរួចហើយ គេមិនគួរលើកបញ្ហាភាពអាចទួលយកបាននៃឯកសារនោះមកដោះស្រាយទៀតទេ។

មេធាវីការពារក្តីលោក **Francois Roux** បានអះអាងថា ឯកសារទាំងពីរគួរត្រូវបដិសេធចោល បើយោងតាមវិធាន ៨៧(៣) ព្រោះថាឯកសារនោះមិនមានលក្ខណៈគតិយុត្ត *"មានភាពមិនសមស្របដើម្បីបញ្ជាក់ពីអង្គហេតុ ដែលត្រូវអះអាង"* ហើយជាឯកសារមិនពាក់ព័ន្ធ និងច្រំដែល។ ទោះបីជាយ៉ាងណាក៏ដោយ ពាក់ពន្ធ័នឹងកង្វល់ទាក់ទងនឹងរបាយការណ៍របស់ **ឈិន សុធី** លោក **Roux** បានពន្យល់ថា **ឌុច** នឹងមានឆន្ទៈផ្តល់ចម្លើយ ប្រសិនបើអត្ថបទច្បាប់ដើមត្រូវបានផ្តល់ដោយសហព្រះរាជអាជ្ញា ។

**បទសម្ភាសន៍ ឌុច ដោយឧត្តមស្នងការសហប្រជាជាតិ (UNOHCHR) និងការអះអាងអំពីការបង្ខិតបង្ខំ :** យោងតាមការសួរដេញដោលកាលពីសប្ដាហ៍មុន អំពីការទទួលយកនូវបទសម្ភាសន៍របស់ជនជាប់ចោទ ដែលធ្វើឡើងដោយលោក **Christophe Peschoux** កាលពីថ្ងៃពុធ លោកចៅក្រម **Lavergne** បានសួរជនជាប់ចោទ អំពីកាលៈទេសៈពេលដែលធ្វើបទសម្ភាសន៍។ ខណៈដែលតុលាការមិនទាន់ធ្វើសេចក្ដីសម្រេចលើការទទួលយកឯកសារដែលមានបញ្ហានេះ លោកចៅក្រម **Lavergne** បានបំភ្លឺថា សំណួរគួរត្រូវបិតក្រោមកាលៈទេសៈពេលដែលធ្វើបទសម្ភាសន៍ និងមិនមែនអំពីអត្ថន័យនៃការធ្វើសម្ភាសន៍ទេ។

នៅពេលឆ្លើយទៅនឹងសំណួរនេះ **ឌុច** បានអះអាងថា លោក **Peschoux** បានស្រែកដាក់គាត់ ក្នុងកំឡុងពេលធ្វើសម្ភាសន៍។ គាត់បានបញ្ជាក់ទៀតថា គាត់មិនត្រូវបានជូនដំណឹងជាមុនពីគោលបំណងនៃការធ្វើសម្ភាសន៍ទេ ដោយគាត់ធ្វើដំណើរទៅកាន់កន្លែងសម្ភាសន៍ដោយយល់ថា ពួកគេនឹងធ្វើការពិភាក្សាអំពីការសាងសង់សាលារៀន។ **ឌុច** បាននិយាយថា ការធ្វើសម្ភាសន៍ គឺដូចជាការសួរចម្លើយ ពីព្រោះលោក **Peschoux** គាត់មានអាណត្តិពីអង្គការសហប្រជាជាតិ ដូច្នេះគាត់មានសិទ្ធិក្នុងការចោទសួរទៅជនជាប់ចោទ ដែលពេលនោះធ្វើឱ្យ **ឌុច** មានអារម្មណ៍ថា *"គាត់ត្រូវតែឆ្លើយតបចំពោះសំណួរ"*។ ការចោទប្រកាន់នោះ បានបន្ថែមទៅកាន់អំណះអំណាងមុនរបស់មេធាវីការពារក្ដី **Francois Roux** អំពីឯកសារមិនមានស្ថានភាពគតិយុត្តនៃការធ្វើសម្ភាសន៍ និងបញ្ហាស្មុគស្មាញផ្សេងទៀតនៃការប្រើប្រាស់ឯកសារ ។

***ការប្រកាសលើកពេលសម្រេចលើបញ្ហាដោះលែងជនជាប់នៅក្រៅឃុំបណ្ដោះអាសន្ន*** **:** នៅថ្ងៃព្រហស្បតិ៍ ប្រធានអង្គជំនុំជម្រះបានប្រកាសលើកការសម្រេចលើបញ្ហាដោះលែងជនជាប់ឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ដែលបានស្នើសុំដោយមេធាវីការពារក្ដីកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៩។ អង្គជំនុំជម្រះ បានប្រកាសថា សេចក្ដីសម្រេចលើការដោះលែងនឹងត្រូវលើកទៅសម្រេចនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩។ យោងតាមវិធាន៨២(៣) *អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចឱ្យបានឆាប់រហ័សដែលអាចធ្វើទៅបាន និងគ្រប់ករណីទាំងអស់ ក្នុងរយៈពេលមិនឱ្យលើសពី ៣០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ លើកលែងតែមានកាលៈទេសៈពិសេសដែលតំរូវឱ្យមានរយៈពេលយូរជាងនេះ។* ការពន្យាពេលរហូតដល់ ៤៥ថ្ងៃ ដោយសារមូលហេតុតែ សំណុំរឿងនេះនៅតុលាការយោធា ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ និងចាំបាច់ក្នុងការពិភាក្សា អង្គជំនុំជម្រះបានស្នើទៅតុលាការយោធា ដើម្បីផ្ដល់សំណុំរឿងនេះ។ សំណុំរឿងនេះទើបតែទទួលបានមួយសប្ដាហ៍មុនបុណ្យចូលឆ្នាំខ្មែរ ហើយតំរូវឱ្យមានពេលគ្រប់គ្រាន់ក្នុងការបកប្រែ ពេលវេលាសមរម្យដល់ភាគីក្នុងការផ្ដល់យោបល់ និងដោយសារពីរសប្ដាហ៍ខាងមុខជាថ្ងៃបុណ្យចំរើនព្រះជន្មព្រះករុណា ជាហេតុនាំឱ្យមានការពន្យាពេលនេះ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និង ការការពារ និងគាំទ្រសាក្សី និងជនរងគ្រោះ

***វត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី*** **:** វត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅសប្ដាហ៍ទីបីនៃដំណើរការកាត់ទោសឌុចនេះ មានចំនួនតែបីរូបប៉ុណ្ណោះ។

***តម្រូវការឱ្យអង្គជំនុំជម្រះថ្លែងពី សិទ្ធិ កាតព្វកិច្ច និង ឋានៈរបស់សាក្សីមុនការចោទសួរ*** **:** ក្នុងកំឡុងពេលចោទសួរសាក្សី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញឱ្យឃើញពីកខ្វល់ និងការព្រួយបារម្ភទៅលើសុវត្ថិភាពទូទៅរបស់សាក្សី ជាពិសេសសាក្សី **ចាន់ ខន**។ សំណួរមួយដែលបានចោទសួរដោយមេធាវីដើមបណ្តឹងក្រុម២ *ថាតើសាក្សីមានអារម្មណ៍ងាយស្រួលក្នុងការផ្តល់សក្ខីកម្មដែរឬទេ នៅពេលស្ថិតនៅក្នុងបន្ទប់រួមជាមួយជនជាប់ចោទ*។ វាជាការល្អ នៅពេលតាំងសំណួរអ្វីមួយដែលបានកើតឡើង *ថាតើសាក្សីបានឆ្លើយនូវការពិត* ហើយប្រហែលជាការប្រសើរ ប្រសិនបើអង្គជំនុំជម្រះបានលើកបញ្ហានេះមុនលើកបញ្ហាពាក់ព័ន្ធជនរងគ្រោះ និងសាក្សីដែលត្រូវការការពារ ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ជាជាងភាគីជាអ្នកលើកមុននឹងចាប់ផ្តើមផ្តល់សក្ខីកម្ម។

***យន្តការការពារសាក្សី*** **:** ដោយសារតែករណីនេះកើតមាននៅសប្តាហ៍មុន ការផ្តល់នូវរហស្សនាមដល់សាក្សីមិនត្រូវបានយកមកប្រើ ក្នុងកំឡុងពេលសួរដេញដោល ហើយអង្គជំនុំជម្រះក៏មិនបានលើកឡើងនូវបញ្ហានេះ។

***សំណួរច្រំដែល*** **:** អង្គជំនុំជម្រះបានដាស់តឿនជាច្រើនលើកច្រើនសារក្នុងការប្រុងប្រយ័ត្ននូវសំណួរច្រំដែល។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានដាស់តឿនកើនរំលឹកភាគីមិនឱ្យតាំងសំណួរច្រំដែល អំឡុងពេលមានការជំទាស់ដោយមេធាវីការពារ អំពីរបៀបដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប៉ុនប៉ងសួរសំណួរទៅជនជាប់ចោទ។ ប្រធានអង្គជំនុំជម្រះ មិនបានលើកឡើងដោយផ្ទាល់នូវគំនិតជំទាស់ ត្រឹមតែរំលឹកដល់មេធាវីដើមបណ្តឹងកុំឱ្យសួរសំណួរច្រំដែល នៅពេលដែលជនជាប់ចោទបានលើកឡើងរួចហើយនូវការបដិសេធមិនឱ្យមានសំណួរច្រំដែល។ ទោះបីជាយ៉ាងណា គួរឱ្យកត់សំគាល់ថា ផ្ទុយមកវិញ កាលពីសវនាការថ្ងៃច័ន្ទ ការតទល់រវាងជនជាប់ចោទ និងសាក្សីមុន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានតាំងសំណួរច្រើនទេទៅសាក្សី **ចាន់ វឿន** នេះប្រហែលជាដោយសារ ពួកគេមិនចង់ឱ្យអង្គជំនុំជម្រះឃើញកាន់តែច្បាស់នូវមន្ទិលសង្ស័យទៅលើសក្ខីកម្មនេះ បន្ទាប់ពីអង្គជំនុំជម្រះចោទសួរ។ ម្យ៉ាងវិញទៀត បណ្តាលមកពីកំហុសនៃការបកប្រែ ដែលធ្វើឱ្យការតាំងសំណួររបស់ភាគីជាសំណួរច្រំដែល (សូមមើល ចំណុចនៃបញ្ហានៃការបកប្រែនៅក្នុងដំណើរការគ្រប់គ្រងនីតិវិធីជំនុំជម្រះ)។

## ៤. ការគ្រប់គ្រងផ្នែកតុលាការ

***ការគ្រប់គ្រងផ្នែកតុលាការ :*** ដំណើរការនីតិវិធីនាសប្តាហ៍នេះបានប្រព្រឹត្តទៅយ៉ាងរលូន។ នៅថ្ងៃទី៣ នៃសប្តាហ៍នេះ អង្គជំនុំជម្រះបានពន្យាវែងសំរាប់សម្រាកអាហារថ្ងៃត្រង់ ដូច្នេះដំណើរការសវនាការ បានបន្តដោយឥតសម្រាកនៅពេលរសៀល។ ចំណែកឯ ថ្ងៃទី៤ ដំណើរការសវនាការចាប់ផ្តើមយឺតប្រមាណជា ៣០នាទី និងបញ្ចប់ត្រឹមថ្ងៃត្រង់។ ការផ្អាកសវនាការមុនម៉ោងកំណត់ ត្រូវបានប្រកាសឡើងដោយអង្គជំនុំជម្រះ ដោយករណីចាំបាច់ ដើម្បីទុកពេលសម្រាប់មន្ត្រីតុលាការធ្វើការដោះស្រាយបញ្ហាដែលនៅសេសសល់ត្រូវសម្រេច។

សរុបសេចក្តីមក អង្គជំនុំជម្រះទំនងជាធ្វើការប្រឹងប្រែងគួរឱ្យកោតសរសើរ ដើម្បីឱ្យប្រាកដថា ដំណើរការនីតិវិធីប្រព្រឹត្តទៅដោយមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងពេលវេលា។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមឃ្លាំមើលតុលាការបានកត់សំគាល់ឃើញ

ថា ជាលទ្ធផលមានការសម្រេចមួយចំនួនដែលត្រូវធ្វើ ហើយបានលើកឡើងដោយអង្គជំនុំជម្រះ ក្រោយពីភាគីបានលើកឡើងអំពីបញ្ហា។ ម្យ៉ាងទៀតក៏ទំនងជានឹងមានការផ្លាស់ប្តូរមួយចំនួន ត្រូវធ្វើការសម្រេចចំពោះបញ្ហាដូចគ្នាដែលបានលើកឡើង ដោយសារតែមិនមានមូលហេតុច្បាស់លាស់។ ឧទាហរណ៍ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបានតទល់ជាមួយសាក្សី ពាក់ព័ន្ធនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលពីមុនអនុញ្ញាតឱ្យប្រើក្នុងការសាកសួរ។ សាក្សីបានបញ្ជាក់ថា គាត់មិនបានចងចាំកិច្ចសម្ភាសន៍ដែលបានធ្វើឡើងនោះទេ (ដែលត្រូវបានបាត់ន័យដោយសារតែកំហុសនៃការបកប្រែ) ហើយអង្គជំនុំជម្រះបានប្តូរការសម្រេចរបស់ខ្លួនភ្លាមៗវិញ។ បញ្ហាកើតឡើងមិនច្បាស់អំពីមូលហេតុពិត ដែលថា សាក្សីមិនអាចចាំបាននូវកិច្ចសម្ភាសន៍ជាដើមចមនៃការហាមប្រាមមេធាវី មិនឱ្យធ្វើការតទល់ជាមួយសាក្សី អំពីខ្លឹមសារដែលមាន។

***កង្វល់ពាក់ព័ន្ធនឹងការបកប្រែភាសា :*** មានកង្វល់ពីរពាក់ព័ន្ធនឹងការបកប្រែភាសា ទីមួយ គឺការបកប្រែឯកសារនៅក្នុងសំណុំរឿងជាពិសេសឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូចបានចង្អុលបង្ហាញដោយសហមេធាវីអន្តរជាតិលោក **Francois Roux** ការបកស្រាយជាភាសាខ្មែរ និងបារាំង ពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍ សាក្សីជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលមានកាលបរិច្ឆេទខុសគ្នា។ លោក **Roux** បានលើកបញ្ហានេះឡើងជាមូលដ្ឋានមួយ ដែលបង្ហាញថាឯកសារមិនមានលក្ខណៈសមស្រមដែលត្រូវប្រើក្នុងដំណើរក្តីតាមផ្លូវច្បាប់។

បញ្ហាផ្សេងទៀត គឺការធ្លាក់ចុះនៃការបកប្រែ ដែលបង្កើតឱ្យមានការឆ្លើយតបដោយច្របូកច្របល់ កំឡុងពេលសាកសួរមានការអាក់អន់ស្រពន់ចិត្តពីសាក្សី ហើយសូម្បីតែអ្វីបានលើករួចមកហើយ ក៏ត្រូវបានរារាំងដោយអង្គជំនុំជម្រះមិនឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើការសាកសួរ។ ឧទាហរណ៍ នៅត្រង់ចំណុចមួយ សាក្សី **ចាន់ ខន** ពេលផ្តល់សក្ខីកម្ម គាត់បានចង្អុលបង្ហាញថា គាត់ចង់ឆ្លើយសំណួរដោយស្មោះត្រង់ ប្រសិនបើគេប្រើឃ្លាឃ្លោងក្នុងលក្ខណៈសាមញ្ញ។ ទោះបីជាយ៉ាងណាក៏ដោយសាក្សីបានជួបប្រទះនូវសំណួរពិបាក ប្រហែលជាមិនមែនដោយសារតែកំហុសរបស់ភាគីប្រើពាក្យទេ តែដោយសារតែការបកប្រែព្រោះតែប្រើប្រាស់ពាក្យស្មុគស្មាញ ។ សហមេធាវីការពារក្តីអន្តរជាតិបានលើកឡើងនូវបញ្ហានេះដល់អង្គជំនុំជម្រះ ដោយចាត់ទុកថាបញ្ហាចោទនៃការបកប្រែកាន់តែដុនដាបឡើង ។ ជំហរនេះត្រូវបានគាំទ្រដោយភាគី ហើយអង្គជម្រះបានសម្រេចថា នឹងចាត់វិធានការជាជំហានៗ ដើម្បីដោះស្រាយបញ្ហា។

***វិន័យក្នុងសាលសវនាការ :*** ឥរិយបថដែលភាគីបានថ្លែងតទល់ជាមួយជនជាប់ចោទត្រូវបានលើកឡើងនាសប្តាហ៍ទី៣ ក្នុងកំឡុងពេលសាកសួរ ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២។ បញ្ហានេះត្រូវបានលើកឡើងម្តងទៀត នៅពេលភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមបានតទល់ជាមួយជនជាប់ចោទ ខណៈពេលនៃសក្ខីកម្មរបស់សាក្សី **ចាន់ ខន**។ លោក **Roux** បានចោទសួរអំពីឥរិយាបថរបស់មេធាវី ហើយទាមទារឱ្យអង្គជំនុំជំរះបង្គាប់ឱ្យមេធាវីប្រើពាក្យគួរសមពេលចោទសួរ ដោយសារតែនីតិវិធីច្បាប់មិនមែនជាការប្រកួតប្រដាល់នោះទេ។

ជាបញ្ហា ភាគីត្រូវគោរពនូវការសម្រេចរបស់តុលាការ។ ជាពិសេសទំនងជាកំឡុងពេលចោទសួរសាក្សីលោក **ចាន់ ខន** ដោយមេធាវីអន្តរជាតិក្រុម២ ដោយផ្អែកតាមកិច្ចសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (កិច្ចពិភាក្សាស្តីពីការសម្រេចត្រូវបានលើកឡើងនៅក្នុងផ្នែកនៃការគ្រប់គ្រងផ្នែកតុលាការនៃជំពូកនេះ)។ អង្គជំនុំជម្រះបានចេញបញ្ជាមិនឱ្យមេធាវីចោទសំណួរពាក់ព័ន្ធនឹងឯកសារ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីនៅតែបន្តលើកឡើងសំណួរដែលពាក់ព័ន្ធនឹងឯកសារ ទោះបីជាមានការសម្រេចជាច្រើនដងរបស់អង្គជំនុំជម្រះ ជាលទ្ធផលលោក **Roux** បានសុំអង្គជំនុំជម្រះចេញបញ្ជាមិនឱ្យសាក្សីឆ្លើយសំណួរ។

***វត្តមានអ្នកចូលរួមក្នុងសាលជំនុំជម្រះ :*** បីថ្ងៃដំបូងនៃដំណើរការសវនាការសប្តាហ៍នេះ មានអ្នកចូលរួមតែ ៣០ ទៅ ៥០នាក់ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនអ្នកចូលរួមបានកើនឡើងគួរឱ្យកត់សំគាល់។ មានអ្នកចូលរួមចំនួនជាង ៤០០នាក់ ដោយមានប្រហែល ២០០នាក់ មកពីឃុំ **អមលាំង** ហើយខ្លះទៀតមកពីខេត្តផ្សេងៗ សាកលវិទ្យាល័យ និងអង្គការមិនមែនរដ្ឋាភិបាល។ សប្តាហ៍នេះមានដើមបណ្តឹងរដ្ឋប្បវេណីតែ ៣នាក់ប៉ុណ្ណោះ តែទោះបីជាយ៉ាងណាក៏ដោយ មេធាវីទាំង ៤ក្រុម គឺមានវត្តមាន។

***អវត្តមានសហព្រះរាជអាជ្ញា :*** ទាំងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ លោកស្រី **ជា លាង** និងលោក **Robert Petit** មិនមានវត្តមានកំឡុងពេលសវនាការទេនាសប្តាហ៍នេះ។ លោក **យ៉ែត ចរិយា** និងលោក **តាន់ សេណារ៉ុង** (ផ្លាស់ប្តូរ) ជំនួសសហព្រះរាជអាជ្ញាជាតិ ចំណែកឯលោក **Alex Bates** ជំនួសសហព្រះរាជអាជ្ញាអន្តរជាតិក្នុងពេលសាវនាការ។

***បញ្ហាបច្ចេកទេស :*** ប្រព័ន្ធលកសម្លេងត្រូវបានរំខាន ដែលធ្វើឱ្យមានការរអាក់រអួលដល់ការបកប្រែ កំឡុងពេលសវនាការ។ ជាធម្មតាបញ្ហានេះបណ្តាលមកពីសញ្ញាម្យ៉ាងបញ្ជូនបន្តទៅឧបករណ៍បកប្រែ ដូចជា ទូរស័ព្ទដៃ ដែលត្រូវបានហាមឃាត់មិនឱ្យយកចូលបន្ទប់បកប្រែ រួមទាំងអ្នកបកប្រែ។ អ្វីដែលគួរកត់សំគាល់ជាងនេះទៀត គឺសម្លេងភ្លៀងបានរំខាន និងបណ្តាលឱ្យពិបាកស្តាប់ ជាហេតុធ្វើឱ្យអង្គជំនុំជម្រះសម្រេចផ្អាកសវនាការ ១០នាទី។ ដោយកត់សំគាល់ថា រដូវវស្សាជិតចូលមកដល់ តុលាការគប្បីបំពាក់នូវប្រព័ន្ធមិនឱ្យសំលេងជ្រៀតចូលបាននៅក្នុងបន្ទប់បកប្រែ ។

## ការគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | អាហារថ្ងៃត្រង់ | សំរាក- រសៀល | បញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ច័ន្ទ ២០.០៤.០៩ | ០៩:១០ | ១០:៣៤ – ១១:០០ | ១២:១១ – ១៣:៤០ | ១៤:៤៣- ១៥:០៥ | ១៦:៣០ | ៤ម៉ ៥៧នាទី |
| អង្គារ ២១.០៤.០៩ | ០៩:០៦ | ១០:៣០-១០:៥៥ | ១២:០៥-១៣:៣៥ | ១៤:៤៥-១៥:១៥ | ១៦:២០ | ៤ម៉ ៤៩នាទី |
| ពុធ ២២.០៤.០៩ | ០៩:១០ | ១០:៤៨ – ១១:៣៥ | ១២:១៥ – ១៤:០០ | គ្មាន | ១៦:១៥ | ៤ម៉ ៣៣នាទី |
| ព្រហស្បតិ៍ ២៣.០៤.០៩ | ០៩:៣០ | ១០:៤៥ – ១១:០៧ | | | ១២:២០ | ២ម៉ ២៨នាទី |

**ចំនួនម៉ោងជាមធ្យម :** **៤ម៉ ២០នាទី**

**ចំនួនម៉ោងសរុបសំរាប់សប្តាហ៍នេះ :** **១៦ម៉ ៤៧នាទី**

**ចំនួន ម៉ោង ថ្ងៃ និង សប្តាហ៍ សរុបសំរាប់សវនាការបីសប្តាហ៍ :** **៤៨ម៉** **ថ្ងៃសវនាការ ១១ថ្ងៃ** **សប្តាហ៍ទី៣**

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** ("កម្មវិធី") : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការរវាង U.C. Berkeley War Crimes Studies Center និង East-West Center ។ កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ឬ តុលាការកាត់ទោសខ្មែរក្រហម។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿងរបស់ កាំង ហ្គិចអ៊ាវ ហៅ ឌុច ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលអង្គជំនុំជម្រះ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានសរសេរដោយក្រុមអ្នកឃ្លាំមើលតុលាការដែលដឹកនាំដោយលោកស្រី Michelle Staggs នាយិការង នៃអង្គការ AIJI មានសមាសភាពដូចខាងក្រោម:

**ក្រុមទី១**. - លោកស្រី **ជូ វិនាថ** :ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD

- លោក **ភ័ក្រ្ត សាវ៉ន្ត** : បុគ្គលិកអង្គការ UNOHCHR
- ក. **Yvette Anthony** : សិង្ហបុរី
- ក. **Sybylle Dischler** : ស្វីស
- លោក **Florian Hansen** : អាល្លឺម៉ង់

**ក្រុមទី២** : - ក. **សេក សុវណ្ណា** : មេធាវី អង្គការ CLEC

- លោក **ម៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KIDþ
- ក. **Aviva Nababan** : ឥណ្ឌូនេស៊ី
- ក. **Romana Weber** : ស្វីស
- ក. **Binxin Zhang** : ចិន

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក- អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និង អង់គ្លេស នៅក្នុង www.csdcambodia.org; www.kidcambodia.org និង http://socrates.berkeley.edu/~warcrime/ ។